ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០៧ ខែមេសា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីដំណើរទស្សនកិច្ចនៅប្រទេសជប៉ុន
## របស់គណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ

តបតាមការអញ្ជើញរបស់លោក OTAKE Kenichiro អតីតអគ្គស្នងការភ្នាក់ងារជាតិពន្ធដារនៃប្រទេសជប៉ុន បច្ចុប្បន្ន ជាប្រធានសមាគមគណនេយ្យប្រចាំអាស៊ី ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធ្វើដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុន ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៤ ។ ក្នុងដំណើរទស្សកិច្ចរយៈពេលបីថ្ងៃ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលនិងចូលជួបពិភាក្សាការងារ ទៅតាមកម្មវិធីដែលបានគ្រោងទុកដូចខាងក្រោម ៖


រូបភាព៖ ដោយអគ្គនាយកដ្ឋានពន្ធដារ ២០១៤

### ១- ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ៖

- ឯកឧត្តម **គង់ វិបុល** និងគណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារបានទទួលជួបពិភាក្សាការងារជាមួយក្រុមសវនករជំនាញនៃប្រទេសជប៉ុន ។
  តាមសំណើរបស់សវនករជំនាញទាំងនោះ ក្នុងជំនួបពិភាក្សាដែលមានរយៈពេល ៣០ នាទី ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានធ្វើបទបង្ហាញស្តីពីប្រព័ន្ធពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា និងបទបង្ហាញ ដែលពាក់ព័ន្ធនឹងសក្តានុពលអាជីវកម្ម ក៏ដូចជាគម្រោងវិនិយោគនានារបស់វិនិយោគិនជប៉ុននៅកម្ពុជា ។ ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល បានជម្រាបជូនផងដែរអំពីការកែទម្រង់គោលនយោបាយពន្ធ និងរដ្ឋបាលសារពើពន្ធរបស់ អគ្គនាយកដ្ឋាពន្ធដារ ក្នុងការប្រមូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

- នៅរសៀលថ្ងៃដដែលនោះដែរ ឯកឧត្តម **គង់ វិបុល** បានទទួលជួបពិភាក្សាការងារជាមួយក្រុមអ្នកវិនិយោគទុនធំៗរបស់ជប៉ុន ។ ក្នុងជំនួបពិភាក្សាការងារនេះ វិនិយោគិនជប៉ុនបានស្នើសុំគណៈប្រតិភូធ្វើការពន្យល់អំពីសក្តានុពលវិនិយោគ ការលើកទឹកចិត្តនិងការអនុគ្រោះពន្ធរបស់ប្រទេសកម្ពុជា ដើម្បីអ្នកវិនិយោគទាំងនោះធ្វើការប្រមើលមើលជាមុននឹងសម្រេចចិត្តមកបោះទុនវិនិយោគនៅកម្ពុជា។


រូបភាព៖ ដោយអគ្គនាយកដ្ឋានពន្ធដារ ២០១៤


រូបភាព៖ ដោយអគ្គនាយកដ្ឋានពន្ធដារ ២០១៤

ក្នុងនោះផងដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនអំពីប្រភេទពន្ធសំខាន់ៗដែលអ្នកវិនិយោគត្រូវបំពេញកាតព្វកិច្ច ដូចជាពន្ធលើប្រាក់ចំណេញ (Tax on Profit) អាករលើតម្លៃបន្ថែម (Value Added Tax VAT) ពន្ធលើប្រាក់បៀវត្ស (Tax on Salary) អាករពិសេសលើទំនិញ និងសេវាមួយចំនួន (Specific Tax on Certain Merchandise and Services) ជាដើម ។

បន្ថែមពីលើនេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានផ្សព្វផ្សាយអំពីសក្តានុពលនៃការធ្វើវិនិយោគនៅកម្ពុជា ដែលក្នុងនោះរួមមាន ៖

+ ទីតាំងភូមិសាស្ត្រដែលមានលក្ខណៈជាយុទ្ធសាស្ត្ររបស់កម្ពុជា ពោលគឺស្ថិតនៅចំកណ្តាលនៃបណ្តាប្រជាជាតិអាស៊ីអាគ្នេយ៍

+ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ ខាងមុខ ដែលពេលនោះ លំហូនិងសក្តានុពលទីផ្សារមានដល់ទៅជាង ៦០០ លាននាក់ សម្រាប់ប្រជាពលរដ្ឋនៅទូទាំងអាស៊ីអាគ្នេយ៍ ដែលប្រការនេះ វិនិយោគិនជប៉ុនមិនគួរមើលរំលង ឬសម្លឹងមើលតែទីផ្សារកម្ពុជាដែលមានប្រជាពលរដ្ឋតែជាង ១៥ លាននាក់ នោះទេ ។
+ ក្រៅពីនេះទៀត តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ព្រមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ជាមួយចិន កាន់តែធ្វើឲ្យសក្តានុពលទីផ្សារកើនឡើងដល់ទៅជាង ២០០០ លាននាក់ ដែលនេះគឺជាសក្តានុពលទីផ្សារដ៏ធំសម្បើម ដែលវិនិយោគិនបរទេស ជាពិសេស វិនិយោគិនជាជនជប៉ុន កាន់តែមិនអាចមើលរំលងបាន ។
+ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ក៏គឺជាកត្តារួមចំណែកយ៉ាងសំខាន់មួយផងដែរក្នុងការទាក់ទាញអ្នកវិនិយោគ ។
+ គោលនយោបាយបើកចំហចំពោះគ្រប់វិនិយោគិនបរទេស ។
+ ការលើកទឹកចិត្តដល់អ្នកវិនិយោគ តាមរយៈគោលនយោបាយពន្ធ ដូចជារយៈពេលនៃការលើកលែងពន្ធលើប្រាក់ចំណេញសម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អត្រាសូន្យនៃអាករពិសេស និងការបង់បំណុលពន្ធជាដំណាក់កាលៗ ជាដើម ។
+ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺសក្តានុពលកម្លាំងពលកម្មការងារជាយុវជនមានដល់ទៅជាង ៦៥% នៃប្រជាជនសរុបរបស់កម្ពុជា ។

ចំពោះក្តីកង្វល់របស់វិនិយោគិនដែលបានលើកឡើងទាក់ទិននឹងតម្លៃអគ្គិសនីខ្ពស់ និងមិនទាន់គ្រប់តាមតម្រូវការប្រើប្រាស់ ឯកឧត្តមប្រធានគណៈប្រតិភូបានជម្រាបជូនវិនិយោគិនថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី តាមរយៈគម្រោងវិនិយោគវារីអគ្គិសនីនានា ក្នុងគោលបំណងផ្តល់ជូននូវតម្លៃអគ្គិសនីថោកសមរម្យ ដោយសង្ឃឹមថា ក្នុងរយៈពេលពីរឆ្នាំខាងមុខ កម្ពុជានឹងមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់តាមតម្រូវការ ។

ក្រោយពីបានស្តាប់ប្រកបដោយយកចិត្តទុកដាក់ នូវបទបង្ហាញនិងការបកស្រាយយ៉ាងក្បោះក្បាយរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលរួចមក វិនិយោគិនជប៉ុនភាគច្រើន រួមទាំងសហគ្រាសធុនមធ្យម និងធុនតូចជាច្រើន បានសម្តែងនូវបំណងមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា បង្កើតការងារកាន់តែច្រើនឡើងសម្រាប់ប្រជាពលរដ្ឋខ្មែរ ។

**២- ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ៖**

- នៅព្រឹកថ្ងៃទី០៣ ខែមេសា គណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ បានជួបសម្តែងការគួរសមចំពោះលោក ICHIKAWA អនុប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដើម្បីសម្តែងអំណរគុណចំពោះ JICA ដែលតែងតែផ្តល់ជំនួយបច្ចេកទេសដល់អគ្គនាយកដ្ឋានពន្ធដារកន្លងមក ។
- នៅវេលាម៉ោង ១១ និង ៣០ នាទី ព្រឹកថ្ងៃដដែលនេះដែរ គណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារបានចូលជួបសម្តែងការគួរសមចំពោះលោក AICHI អតីតរដ្ឋមន្ត្រីក្រសួងបរិស្ថាន ផងដែរ ។
- នៅវេលាម៉ោង ១៣:០០ ថ្ងៃដដែលនោះ ឯកឧត្តម **គង់ វិបុល** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ ចូលជួបសម្តែងការគួរសមចំពោះលោក Komura អនុប្រធានគណបក្ស Liberal Democratic Party (LDP) ដែលជាគណបក្សកាន់អំណាចជាង ៦០ ឆ្នាំ មកហើយ ។ ក្នុងជំនួបពិភាក្សានោះ លោក Komura បានកោតសរសើររាជរដ្ឋាភិបាលកម្ពុជា លើកិច្ចការនៃការរក្សាបាននូវស្ថានការណ៍នយោបាយប្រកបដោយស្ថិរភាពល្អប្រសើរ ជាពិសេស គោលនយោបាយកែទម្រង់ស៊ីជម្រៅដែលកំពុងតែបោះជំហានទៅមុខ ប្រកបដោយផ្លែផ្កាល្អ ។

ជាការឆ្លើយតប ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងនូវអំណរគុណ និងបានស្នើសុំឯកឧត្តម Komura ក្នុងនាមរាជរដ្ឋាភិបាលជប៉ុន ដើម្បីផ្តល់ជំនួយលើកិច្ចការបណ្តុះបណ្តាលធនធានមនុស្សទាក់ទងនឹងភាពជាអ្នកដឹកនាំដល់យុវជនកម្ពុជា និយាយជារួម និងដល់យុវមន្ត្រីរាជការពន្ធដារ និយាយដោយឡែក ។

- នៅវេលាម៉ោង ១៤ :០០ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានទទួលជួបជាមួយនាយកប្រតិបត្តិ និងអ្នកយកព័ត៌មានរបស់សារព័ត៌មាន Mainichi Newspaper ដែលជាសារព័ត៌មានដ៏ល្បីល្បាញ និងធំជាងគេបង្អស់របស់ជប៉ុន ព្រមទាំងមានទីស្នាក់ការនៅបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ផងដែរ ដូចជាប្រទេសម៉ាឡេស៊ី ជាដើម ។ អ្នកសារព័ត៌មានបានលើកឡើងនូវសំណួរស្នើឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលធ្វើការបកស្រាយផងដែរ ទាក់ទងទៅនឹង

សភាពការណ៍នយោបាយ និងសក្តានុពលពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។ ឆ្លើយតបនឹងសំណួរដែលបានលើកឡើងទាក់ទងនឹងស្ថិរភាពនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានបញ្ជាក់ជូនថា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ពិតជាមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងសភាពការណ៍នយោបាយបានយ៉ាងល្អប្រសើរ ដើម្បីផ្តល់ទំនុកចិត្តជូនគ្រប់ វិនិយោគិនបរទេស ។

**៣- ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ៖**

- វេលាម៉ោង ១១:00 ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យគណៈប្រតិភូនៃវិទ្យាស្ថានហិរញ្ញវត្ថុ និងសហគ្រិនជប៉ុន ចូលជួបសម្តែងការគួរសម ។ ក្នុងជំនួបនេះផងដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានមានចំណាប់អារម្មណ៍ និងសម្តែងអំណរគុណចំពោះវិនិយោគិនជប៉ុន ដែលជានិច្ចកាលតែងតែបានផ្តល់បរិយាកាសការងារល្អចំពោះកម្មករនិយោជិតជាប្រជាពលរដ្ឋកម្ពុជា ពោលគឺបានផ្តល់កម្រៃពលកម្មសមស្រប និងផ្តល់ទីជម្រកស្នាក់នៅ ព្រមទាំងការហូបចុក បានយ៉ាងសមរម្យ ។
- នៅរសៀលថ្ងៃដដែលនោះដែរ គណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ បានអនុញ្ញាតឲ្យលោក INAGAKI ប្រធានអគ្គស្នងការភ្នាក់ងារពន្ធដារជាតិរបស់ប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម ។ នៅក្នុងជំនួបនេះផងដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានស្នើសុំភ្នាក់ងារពន្ធដារជាតិរបស់ប្រទេសជប៉ុន ផ្តល់ជំនួយបច្ចេកទេសជូនអគ្គនាយកដ្ឋានពន្ធដារ លើកិច្ចការការចៀសវាងការយកពន្ធត្រួតគ្នា ។

ដោយមើលឃើញពីនិន្នាការរបស់វិនិយោគិនជប៉ុនដែលពិតជាមានបំណងមកធ្វើការបណ្តាក់ទុននៅកម្ពុជា ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលយល់ថា នេះគឺជាឱកាសដ៏ល្អដែលកម្ពុជាត្រូវតែចាប់យក ជាពិសេស គោលនយោបាយ កែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយប្រកបដោយគតិបណ្ឌិត បញ្ញាញាណដ៏ឈ្លាសវៃរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នីតិកាលទីប្រាំនៃរដ្ឋសភា បាននិងកំពុងបង្កនូវបរិយាសល្អប្រសើរ និងជំនឿទុកចិត្តខ្ពស់ជូនចំពោះវិនិយោគិនជប៉ុន ក៏ដូចជាវិនិយោគិនបរទេសនានា ក្នុងគោលដៅស្រូបយកទំហំការងារកាន់តែច្រើនជូនប្រជាពលរដ្ឋយើង ។

គណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ បានបញ្ចប់ទស្សនកិច្ចប្រកបដោយលទ្ធផលជាផ្លែផ្កា និងវិលត្រឡប់មកកាន់មាតុភូមិវិញ នៅរាត្រីថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៤ ប្រកបដោយសុវត្ថិភាពខ្ពស់ ។




*រូបភាព៖ ដោយអគ្គនាយកដ្ឋានពន្ធដារ ២០១៤*